ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# ជនគ្រប់រូបដែលជាប់ចោទក្នុងបទល្មើសព្រហ្មទណ្ឌមានសិទ្ធិ ជាក់លាក់មួយចំនួនតាមច្បាប់ជាតិ និងអន្តរជាតិ

| | |
|---|---|
| **ការធ្វើទារុណកម្មខាងផ្លូវចិត្ត និងផ្លូវកាយដោយមន្ត្រីនគរបាល និងអាជ្ញាធរត្រូវបានហាមឃាត់** | ប្រសិនបើនៅដំណាក់កាលណាមួយនៃនីតិវិធី មន្ត្រីនគរបាល ឬអាជ្ញាធរបានប្រើប្រាស់អំពើហិង្សា ឬគំរាមកំហែង ដើម្បីទទួលបានចម្លើយសារភាពរបស់អ្នក អ្នកគួរតែប្រាប់មេធាវីរបស់អ្នក និង/ឬ រាយការណ៍អំពីបញ្ហានេះទៅ តុលាការឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។ ចម្លើយដែលទទួលបានក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬខាងផ្លូវចិត្ត គ្មានតម្លៃជាភស្តុតាងទេ។<br>*មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") មាត្រា ១៤ (៣)(ឆ) នៃកតិកាសញ្ញាអន្តរ ជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") និងមាត្រា ៥ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ("ស.ស.ស.ម")។* |
| **សិទ្ធិយល់ដឹងពីបទចោទប្រកាន់ និងមូលហេតុនៃការចោទប្រកាន់** | អ្នកមានសិទ្ធិទទួលបានព័ត៌មានពីចៅក្រមអំពីបទល្មើសដែលត្រូវចោទប្រកាន់ ពេលវេលា និងទីតាំងដែលបទល្មើសត្រូវបានប្រព្រឹត្ត។<br>*មាត្រា ១៤៣ និងមាត្រា ៣២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និង មាត្រា ១៤ (៣)(ក) នៃ ក.អ.ស.ព.ន។* |
| **សិទ្ធិនៅស្ងៀម** | អ្នកអាចឆ្លើយ ឬមិនឆ្លើយដោយសេរី ទៅនឹងសំណួរណាមួយដែលត្រូវបានសួរមកកាន់អ្នក។ ប្រសិនជាអ្នកសម្រេចមិនឆ្លើយតបទៅនឹងសំណួរ នោះតុលាការមិនអាចយកការនៅស្ងៀមរបស់អ្នកធ្វើជាមូលដ្ឋានក្នុងការសម្រេចអំពីទោសកំហុសរបស់អ្នកឡើយ។ តុលាការសម្អាងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនតែទៅលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ឬដែលត្រូវគេបង្ហាញនៅពេលសវនាការប៉ុណ្ណោះ។<br>*មាត្រា ១៤៣ និងមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។* |
| **សិទ្ធិទទួលបានមេធាវី** | ប្រសិនជាអ្នកត្រូវបានចោទប្រកាន់ក្នុងបទឧក្រិដ្ឋ ឬអ្នកជាអនីតិជន (អាយុក្រោម ១៨ ឆ្នាំ) អ្នកត្រូវតែមានមេធាវីការពារ។ ក្នុងករណីដែលអ្នកគ្មានមេធាវី តុលាការគប្បីផ្តល់មេធាវីដល់អ្នក បើពុំដូច្នោះទេ អ្នកអាចធ្វើការស្នើសុំទៅចៅក្រមដើម្បីរកមេធាវីឲ្យអ្នកបាន។<br>ប្រសិនជាអ្នកត្រូវបានចោទប្រកាន់ក្នុងបទមជ្ឈិម នោះការមានមេធាវីការពារមិនមែនជាការចាំបាច់ដែលតម្រូវដោយច្បាប់នោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកនៅតែមានសិទ្ធិក្នុងការពឹងពាក់មេធាវីផងដែរ ដើម្បីការពារឧត្តមប្រយោជន៍របស់អ្នក។ ការឆ្លងឆ្លើយរវាងអ្នក និងមេធាវីរបស់អ្នកក្រៅសវនាការមិនអាចយកមកធ្វើជាភស្តុតាងបានឡើយ។<br>*មាត្រា ៣០០ មាត្រា ៣០១ និងមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៤ (៣)(ឃ) នៃ ក.អ.ស.ព.ន។* |
| **សិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោស** | អ្នកមានសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស រហូតដល់តុលាការរកឃើញថាអ្នកមានទោសដែលប្រកាសជាស្ថាពរ។ គ្រប់ការផ្តន្ទាទោស ត្រូវតែធ្វើឡើងដោយផ្អែកទៅលើភស្តុតាងដែលបានដាក់ចំពោះមុខតុលាការ ហើយការដាក់ទោសត្រូវតែធ្វើឡើងដោយគ្មានវិមតិសង្ស័យ។ វិមតិសង្ស័យត្រូវបានជាអត្ថប្រយោជន៍ដល់ជនជាប់ចោទជានិច្ច។<br>*មាត្រា ៣២១ និង មាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ មាត្រា ១៤ (២) នៃ ក.អ.ស.ព.ន និង មាត្រា ១១(១) នៃ ស.ស.ស.ម។* |
| **សិទ្ធិមានសេរីភាព** | ជាគោលការណ៍ ជនត្រូវចោទត្រូវមានសេរីភាព។ អ្នកមានសិទ្ធិស្នើសុំនៅក្រៅឃុំបាននៅគ្រប់ដំណាក់កាលនៃនីតិវិធី។ អ្នក ឬ មេធាវីរបស់អ្នកគួររៀបចំឯកសារ រួចដាក់ជូនទៅតុលាការដើម្បីសម្រេច។ អ្នកអាចដាក់ពាក្យសុំនេះជាថ្មីម្តងទៀតបានទៅចៅក្រមស៊ើបសួរ ឬទៅសភាស៊ើបសួរក្នុងអំឡុងពេល ១ ខែ ក្រោយពេលដែលពាក្យសុំមុន ត្រូវបានបដិសេធ។<br>*មាត្រា ២០៣ ដល់ មាត្រា ២១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣២ នៃរដ្ឋធម្មនុញ្ញ មាត្រា ៩ នៃ ក.អ.ស.ព.ន និងមាត្រា ៣ នៃ ស.ស.ស.ម។* |
| **សិទ្ធិក្នុងការកោះហៅសាក្សី** | អ្នកអាចស្នើឲ្យតុលាការកោះហៅសាក្សីដែលព្រះរាជអាជ្ញាមិនបានកោះហៅ ដោយអ្នកត្រូវចេញសោហ៊ុយចំណាយខ្លួនឯង។<br>*មាត្រា ២៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ១៤ (៣)(ង) នៃ ក.អ.ស.ព.ន។* |
| **សិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ និងសិទ្ធិធ្វើបណ្តឹងសាទុក្ខ** | អ្នកមានសិទ្ធិក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមតុលាការថ្នាក់ដំបូង និងមានសិទ្ធិធ្វើបណ្តឹងសាទុក្ខចំពោះសាលដីកាសាលាឧទ្ធរណ៍។ អ្នក ឬ មេធាវីរបស់អ្នកគួររៀបចំឯកសារដាក់ពាក្យបណ្តឹងឧទ្ធរណ៍ - បណ្តឹងសាទុក្ខ និងមូលហេតុនៃបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រម ឬមូលហេតុនៃបណ្តឹងសាទុក្ខចំពោះសាលដីកា ក្នុងអំឡុងពេល ១ ខែ យ៉ាងយូរ បន្ទាប់ពីការប្រកាសសាលក្រម ឬសាលដីកានោះ។<br>*មាត្រា ៣៧៥ ដល់មាត្រា ៣៧៧ មាត្រា ៣៨២ មាត្រា ៤១៩ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និង មាត្រា ១៤ (៥) នៃ ក.អ.ស.ព.ន។* |


មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

USAID
ជំនួយពីពលរដ្ឋអាមេរិក

EAST · WEST MANAGEMENT INSTITUTE
Program on Rights and Justice (PRAJ)
កម្មវិធីសិទ្ធិ និង យុត្តិធម៌ (ប្រាជ្ញ)

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER